# ស្ថានទូតសហរដ្ឋអាមេរិក ភ្នំពេញ, កម្ពុជា

សេចក្តីប្រកាសពត៌មាន ក្នុងឆ្នាំ២០១៤

Share

បកប្រែ: English

## កម្មវិធីគំរោងកែលំអការអប់រំកំរិតមូលដ្ឋាននៅកម្ពុជារបស់ **USAID** ជួយដល់យុវជនកម្ពុជាចំនួន៨១០០០នាក់

ចេញថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៤

គំរោងរយៈពេល ៥ ឆ្នាំ ស្តីពីការកែលំអការអប់រំកំរិតមូលដ្ឋាននៅកម្ពុជា(IBEC) ដែលគាំទ្រដោយទីភ្នាក់ងារសហរដ្ឋអាមេរិកសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) បានប្រារព្ធធ្វើសិក្ខាសាលាបិទបញ្ចប់គំរោង របស់ខ្លួននៅថ្ងៃទី២៥-២៦ ខែសីហានេះ ។ ក្រោមគំរោងកម្មវិធី (IBEC) មានសិស្សកំរិតបឋមសិក្សា និងកំរិត វិទ្យាល័យ ចំនួនជាង ៨១ ០០០ នាក់ ទទួលបាននូវគុណភាពនិងការអប់រំ ជាមូលដ្ឋានកាន់តែប្រសើរសំរាប់ យុវជនកម្ពុជា តាមរយៈ អំណោយថវិកាសំរាប់ការកែលំអសាលារៀន ការរៀបចំ និងតេស្តសាកល្បងលើកម្មវិធីសិក្សា ការបណ្តុះបណ្តាលគ្រូ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល និងមន្ត្រីរដ្ឋាភិបាល ។




នៅក្នុងសិក្ខាសាលាបិទគំរោង ដែលចូលរួមជាអធិបតី ដោយឯកឧត្តមបណ្ឌិត ហង់ ជួនណារ៉ុន រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡាកម្ពុជា និងលោកស្រី Rebecca Black នាយិកាទីភ្នាក់ងារ USAID ប្រចាំកម្ពុជា។

គំរោងកែលំអការអប់រំកំរិតមូលដ្ឋាននៅកម្ពុជា (IBEC) បានផ្តល់អាហារូបករណ៍ដល់សិស្សចំនួន ៧៥០០នាក់នៅថ្នាក់បឋមសិក្សា និងសិស្សចំនួន ២ ២៤៥ នាក់នៅថ្នាក់វិទ្យាល័យ ដើម្បីធានាថាសិស្សទាំងនោះមិនបោះបង់ចោលការសិក្សា។ អត្រាសិស្សដែលបញ្ចប់ការសិក្សានៅថ្នាក់ទី៧នៅក្នុងកម្មវិធី នេះមានចំនួន ៨៥% ចំណែកអត្រាថ្នាក់ជាតិមានតែ ៤៧% ប៉ុណ្ណោះ។

បុគ្គលិករបស់គំរោងកម្មវិធី IBEC ធ្វើការងារជាមួយមន្ត្រីនៅតាមសាលារៀននានា ដើម្បីបង្កើតបន្ទប់ កុំព្យូទ័រចំនួន ២៦ ដើម្បីអោយសិស្សកម្ពុជារាប់ពាន់នាក់នៅតាមជនបទមានលទ្ធភាព រៀនពីបច្ចេកទេសសារ គមនាគមន៍និងព័ត៌មាន។ ក្រុមការងារគំរោងក៏បានរៀបចំនិងជួយដល់ការអនុវត្តកម្មវិធីមេរៀនចំនួន ២៨ ស្តីពីបំនិនជីវិតនៅតាមវិទ្យាល័យដែលត្រូវបានទទួលស្គាល់និងអនុម័តអោយប្រើដោយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការគាំទ្រផែនការជាយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៤ - ២០១៨ របស់ក្រសួងអប់រំយុវជននិងកីឡា។

នៅក្នុងសិក្ខាសាលាបិទគំរោង ដែលចូលរួមជាអធិបតី ដោយឯកឧត្តមបណ្ឌិត ហង់ ជួនណារ៉ុន រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡាកម្ពុជា និងលោកស្រី Rebecca Black នាយិកាទីភ្នាក់ងារ USAID ប្រចាំកម្ពុជា។

លោកស្រី Rebecca Black បានមានប្រសាសន៍ថា “យើងគាំទ្រកំណែទំរង់បច្ចុប្បន្នក្នុងវិស័យអប់រំ ហើយសង្ឃឹមថា សកម្មភាពបែបថ្មីនៅក្នុងសាលារៀនដែលគំរោងរបស់យើងជួយ អាចធ្វើជាគំរូសំរាប់ប្រទេសកម្ពុជា”។

## ប្រវត្តសង្ខេបរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ **(USAID)**

ទីភ្នាក់ងារ USAID ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៦១ ដោយលោកប្រធានាធិបតីអាមេរិក John F. Kennedy ហើយដើរតួនាទីជាទីភ្នាក់ងារនាំមុខគេក្នុងការផ្តល់ជំនួយបរទេសរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក។ តាំងពីឆ្នាំ១៩៩២ មក ទីភ្នាក់ងារ USAID បានចំណាយថវិកាប្រហែល ១ ពាន់លានដុល្លាអាមេរិកសំរាប់ការអភិវឌ្ឍន៍នៅកម្ពុជា។

ចំពោះព័ត៌មានបន្ថែមស្តីពីគំរោង IBEC សូមចុចត្រង់នេះ ឬត្រង់នេះ។

គេហទំព័រនេះគ្រប់គ្រងដោយក្រសួងការបរទេសសហរដ្ឋអាមេរិក។ ទស្សនៈឬគោលនយោបាយស្តីពីភាពជាឯកជន របស់អត្ថបទឬគេហទំព័រភ្ជាប់ ដែលនៅក្រៅគេហទំព័ររបស់យើង មិនឆ្លុះបញ្ចាំងពីទស្សនៈរបស់រដ្ឋាភិបាលអាមេរិកទេ។